**ថ្ងៃទី 5 ខែវិច្ឆិកា៖ ការបោះឆ្នោ តទូទៅ**

**ចុះឈ្មោះបោះឆ្នោត ......................................... 21 តុលា**
**ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ ....22 តុលា- 5 វិច្ឆិកា**
**ផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រមកវិញ..................... 5 វិច្ឆិកា**

សន្លឹកឆ្នោតបោះតាមសំបុត្រត្រូវតែបិទតែមប្រៃសណីយ៍នៅថ្ងៃ ឬមុនថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024 និងទទួលដោយការិយាល័យបោះឆ្នោតនៅក្នុងខោនធី មិនលើសពីថ្ងៃទី 12 ខែវិច្ឆិកា ឆ្នាំ 2024។

## តើខ្ញុំត្រូវចុះឈ្មោះបោះឆ្នោតដោយរបៀបណា?

ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋកាលីហ្វ័រញ៉ាបាន អ្នកត្រូវតែ៖

- ជាពលរដ្ឋអាមេរិក និងជាអ្នករស់នៅរដ្ឋកាលីហ្វ័រញ៉ា
- មានអាយុចាប់ពី 18 ឆ្នាំឡើងទៅនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្ននេះមិនជាប់ក្នុងពន្ធនាគាររដ្ឋ ឬសហព័ន្ធសម្រាប់ការផ្តន្ទាទោសបទឧក្រិដ្ឋ និង
- បច្ចុប្បន្ននេះ តុលាការមិនបានរកឃើញថា អ្នកអសមត្ថភាពផ្លូវចិត្ត ក្នុងការបោះឆ្នោតនោះទេ។

ប្រសិនបើអ្នកមានសិទ្ធិ អ្នកអាចចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នកតាមអ៊ីនធឺណិតតាមគេហទំព័រ [registertovote.ca.gov](registertovote.ca.gov)។ ប្រសិនបើអ្នកចង់បំពេញទម្រង់បែបបទជាក់ស្តែង ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតអាចរកបាននៅការិយាល័យប្រៃសណីយ៍ និងបណ្ណាល័យ។

អ្នកត្រូវតែចុះឈ្មោះឡើងវិញពេលណាដែលអ្នកផ្លាស់លំនៅ ប្តូរឈ្មោះ ឬប្តូរនិន្នាការគណបក្សនយោបាយរបស់អ្នក។

## តើខ្ញុំអាចចុះឈ្មោះជាមុន ដើម្បីបោះឆ្នោតនៅរដ្ឋកាលីហ្វ័រញ៉ាបានទេ ?

ប្រាកដណាស់ ដើម្បីចុះឈ្មោះបោះឆ្នោតក្នុងរដ្ឋកាលីហ្វ័រញ៉ាបាន អ្នកត្រូវតែ៖

- មានអាយុ 16 ឬ 17 ឆ្នាំ ហើយ
- បំពេញគ្រប់លក្ខខណ្ឌសិទ្ធិផ្សេងទៀត ក្នុងការបោះឆ្នោត។

បន្ទាប់ពីការចុះឈ្មោះជាមុន អ្នកនឹងត្រូវ ចុះឈ្មោះបោះឆ្នោតដោយស្វ័យនៅថ្ងៃខួបកំណើត 18 ឆ្នាំរបស់អ្នក។ ចូលទៅកាន់ [registertovote.ca.gov](registertovote.ca.gov) ដើម្បីចុះឈ្មោះបោះឆ្នោតជាមុន។

## ចុះបើខ្ញុំខកខានថ្ងៃផុតកំណត់ ចុះឈ្មោះបោះឆ្នោត?

ប្រសិនបើអ្នកខកខានកាលបរិច្ឆេទកំណត់ចុះឈ្មោះបោះឆ្នោត 14 ថ្ងៃមុនការបោះឆ្នោត អ្នកនៅតែអាចទៅកាន់ការិយាល័យបោះឆ្នោតនៅក្នុងខោនធី មណ្ឌលបោះឆ្នោត ឬកន្លែងបោះឆ្នោតនៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោត ដើម្បីបញ្ចប់ដំណើរការចុះឈ្មោះអ្នកបោះឆ្នោតតាមលក្ខខណ្ឌ (ជារឿយៗសំដៅថា "ការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយ")។ អ្នកនឹងត្រូវបំពេញ កាតចុះឈ្មោះអ្នកបោះឆ្នោត ហើយនឹងទទួលបានសន្លឹកឆ្នោត។ នៅពេលដែលមន្ត្រីរៀបចំបោះឆ្នោតនៅក្នុងខោនធីបានផ្ទៀងផ្ទាត់ការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក ការបោះឆ្នោតរបស់អ្នកនឹងត្រូវបានរាប់។ ទាក់ទងការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នក ដើម្បីទទួលបានព័ត៌មានបន្ថែម ឬចូលទៅកាន់គេហទំព័រ [vote.ca.gov](vote.ca.gov)។

## ចុះបើខ្ញុំត្រូវពិនិត្យ ស្ថានភាពការចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំ?

ដើម្បីពិនិត្យមើលស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នករួមទាំងគណបក្សនយោបាយផងដែរ អ្នកអាចប្រើឧបករណ៍ "My Voter Status" (ស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ) តាមគេហទំព័រ [voterstatus.sos.ca.gov](voterstatus.sos.ca.gov)។ អ្នកក៏អាចទូរសព្ទទៅលេខទូរសព្ទទាន់ហេតុការណ៍សម្រាប់អ្នកបោះឆ្នោតរបស់យើងតាមរយៈលេខទូរសព្ទ (800) 345-VOTE (8683) ដើម្បីដឹងស្ថានភាពរបស់អ្នក។

## តើខ្ញុំនឹងទទួលបានសន្លឹកឆ្នោតនៅពេលណា?

មន្ត្រីរៀបចំបោះឆ្នោតតាមខោនធីនឹងផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រប្រៃសណីយ៍ទៅកាន់អ្នកចុះឈ្មោះបោះឆ្នោតហើយសកម្មទាំងអស់សម្រាប់រាល់ការបោះឆ្នោត ប្រសិនបើពួកគេបានចុះឈ្មោះមុនថ្ងៃផុតកំណត់នៃការចុះឈ្មោះអ្នកបោះឆ្នោត។ ថ្ងៃទី 7 ខែវិច្ឆិកា ឆ្នាំ 2024 គឺជាថ្ងៃចុងក្រោយសម្រាប់ឱ្យខោនធីចាប់ផ្តើមការផ្ញើសន្លឹកឆ្នោតតាមសំបុត្រសម្រាប់ការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីនៅថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024។

## ចុះបើខ្ញុំត្រូវការសន្លឹកឆ្នោតជំនួស?

ប្រសិនបើអ្នកមិនបានទទួលសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក ឬអ្នកបានបាត់ ឬបានធ្វើឱ្យខូចសន្លឹកឆ្នោតដើមរបស់អ្នក អ្នកអាចដាក់ពាក្យសុំសន្លឹកឆ្នោតជំនួសបាន។ មានតែអ្នកចុះឈ្មោះបោះឆ្នោតផ្ទាល់ប៉ុណ្ណោះទើបអាចស្នើសុំសន្លឹកឆ្នោតជំនួសបាន។ ពាក្យស្នើសុំសន្លឹកឆ្នោតជំនួសអាចរកបានតាមគេហទំព័រ [https://elections.cdn.sos.ca.gov/vote-by-mail/pdf/replacement-application.pdf](https://elections.cdn.sos.ca.gov/vote-by-mail/pdf/replacement-application.pdf)។

ពាក្យសុំនេះនឹងត្រូវបានបញ្ជូនត្រឡប់ទៅការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នក។ អ្នកក៏អាចស្នើសុំសន្លឹកឆ្នោតជំនួសពីការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នកតាមទូរសព្ទ អ៊ីមែល ទូរសារ ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។

## តើខ្ញុំនឹងទទួលបានការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតនៅពេលណា ?

អ្នកចុះឈ្មោះបោះឆ្នោតហើយនឹងទទួលបានការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតរបស់រដ្ឋរបស់ពួកគេតាមប្រៃសណីយ៍ពីការិយាល័យ

រដ្ឋលេខាធិការពីរបីសប្តាហ៍មុនថ្ងៃបោះឆ្នោត។ ការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតរបស់រដ្ឋក៏នឹងមាននៅលើគេហទំព័រ voterguide.sos.ca.gov ផងដែរ។ អ្នកក៏នឹងទទួលបានការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតតាមខោនធី ដែលនឹងរួមបញ្ចូលព័ត៌មានអំពីការប្រកួតប្រជែងក្នុងតំបន់ របៀប និងកន្លែងដែលត្រូវបោះឆ្នោត និងសន្លឹកឆ្នោតគំរូ។ ឯកសារទាំងនេះនឹងត្រូវបានផ្ញើដោយការិយាល័យបោះឆ្នោតប្រចាំខោនធីក្នុងតំបន់របស់អ្នក។ អ្នកអាចទាក់ទងការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក ដើម្បីស្នើសុំការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតខោនធី ឬដើម្បីស្វែងយល់បន្ថែមអំពីព័ត៌មានអំពីការបោះឆ្នោតក្នុងតំបន់។

### ចុះបើខ្ញុំត្រូវការការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតរដ្ឋរបស់ខ្ញុំជាភាសាផ្សេង  ឬទម្រង់ ជំនួស?

ការណែនាំអំពីព័ត៌មានអ្នកបោះឆ្នោតទូទាំងរដ្ឋមាន 10 ភាសា។ សំឡេង និងកំណែបោះពុម្ពជាអក្សរពុម្ពធំៗនៃការណែនាំក៏មានផ្តល់ជូនអ្នកបោះឆ្នោតដែលពិការភ្នែក ឬពិបាកមើលផងដែរ។ ចូលទៅកាន់ voterguide.sos.ca.gov ដើម្បីទទួលបានច្បាប់ចម្លងដោយឥតគិតថ្លៃ។

### តើខ្ញុំអាចផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្ររបស់ខ្ញុំទៅវិញដោយរបៀបណា ?

អ្នកអាចផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នកតាមរយៈ៖

- ផ្ញើទៅមន្ត្រីរៀបចំបោះឆ្នោតប្រចាំខោនធីរបស់អ្នក។ សន្លឹកឆ្នោតរបស់អ្នកត្រូវតែមានបិទតែមប្រៃសណីយ៍នៅ ឬមុន ថ្ងៃបោះឆ្នោត ហើយ ត្រូវបានទទួលដោយការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក មិនលើសពី 7 ថ្ងៃ បន្ទាប់ពី ថ្ងៃបោះឆ្នោត
- ទម្លាក់សន្លឹកឆ្នោតរបស់អ្នកទៅក្នុងប្រអប់ទម្លាក់សន្លឹកឆ្នោតនៅក្នុងខោនធីរបស់អ្នក ឬនៅទីតាំងទម្លាក់សន្លឹកឆ្នោត ឬទីតាំងបោះឆ្នោតនៅកន្លែងណាមួយក្នុង រដ្ឋ ឬ
- ស្នើសុំឱ្យនរណាម្នាក់ដែលអ្នកទុកចិត្តឱ្យផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ ដរាបណាពួកគេមិនទទួលបានប្រាក់ឈ្នួលតាមមូលដ្ឋាន សន្លឹកឆ្នោតនីមួយៗ។

### តើខ្ញុំអាចតាមដានសន្លឹកឆ្នោតរបស់ខ្ញុំដោយរបៀបណា ដើម្បីដឹងថាគេទទួលសន្លឹកឆ្នោតនោះហើយឬនៅ?

អ្នកបោះឆ្នោតអាចទទួលបានការជូនដំណឹងស្តីពីស្ថានភាពនៃសន្លឹកឆ្នោតផ្ញើតាមសំបុត្ររបស់ពួកគេដោយចុះឈ្មោះសម្រាប់ប្រើប្រាស់ ឧបករណ៍ "Where's My Ballot?" (តើសន្លឹកឆ្នោតរបស់ខ្ញុំនៅឯណា)។ ចុះឈ្មោះតាមគេហទំព័រ wheresmyballot.sos.ca.gov ដើម្បីទទួលបានបច្ចុប្បន្នភាពអំពីស្ថានភាពនៃសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នកតាមរយៈសារជាអក្សរ (SMS) អ៊ីមែល ឬការហៅជាសំឡេង។

### តើខ្ញុំអាចដឹងថាសន្លឹកឆ្នោតរបស់ខ្ញុំត្រូវបានគេរាប់បានដោយរបៀបណា ?

អ្នកអាចចូលទៅកាន់ "My Voter Status" (ស្ថានភាពអ្នកបោះឆ្នោតរបស់ខ្ញុំ) ដើម្បីរកមើលថាតើ សន្លឹកឆ្នោតរបស់អ្នកត្រូវបានរាប់ឬអត់ ហើយបើមិនត្រូវបានរាប់ទេ មើលថាមកពីហេតុអ្វី តាម voterstatus.sos.ca.gov។

### តើខ្ញុំធ្វើដូចម្តេចដើម្បីស្វែងរកកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោត ឬប្រអប់ ទម្លាក់របស់ខ្ញុំ?

- ចូលទៅកាន់ caearlyvoting.sos.ca.gov ដើម្បីស្វែងរកទីតាំងប្រអប់ទម្លាក់ដែលនៅជិត
- ទាក់ទងការិយាល័យបោះឆ្នោតនៅក្នុងខោនធីរបស់អ្នក
- ហៅទូរសព្ទទៅលេខទូរសព្ទអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ - (800) 345-VOTE (8683) ឬចូលទៅកាន់ voterstatus.sos.ca.gov

អ្នកក៏អាចសាកសួរការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នកផងដែរ ដើម្បីទទួលបានព័ត៌មានថ្មីៗស្តីពីកន្លែងបោះឆ្នោត មណ្ឌលបោះឆ្នោត ឬទីតាំងទន្លាក់សន្លឹកឆ្នោតរបស់អ្នក។

### តើខ្ញុំអាចបោះឆ្នោតបានមុនបានលឿនកម្រិតណា?

ខោនធីរបស់អ្នកអាចផ្តល់ទីតាំងបោះឆ្នោតមុនកាលកំណត់មុននៅមុនថ្ងៃបោះឆ្នោតបាន។ សម្រាប់បញ្ជី សូមចូលទៅកាន់ caearlyvoting.sos.ca.gov។ ថ្ងៃទី 7 ខែវិច្ឆិកា ឆ្នាំ 2024 គឺជាថ្ងៃចុងក្រោយសម្រាប់ឱ្យខោនធីចាប់ផ្តើមការផ្ញើសន្លឹកឆ្នោតតាមសំបុត្រសម្រាប់ការបោះឆ្នោតទូទៅជ្រើសរើសប្រធានាធិបតីនៅថ្ងៃទី 5 ខែវិច្ឆិកា ឆ្នាំ 2024។ ដើម្បីធានាថាសន្លឹកឆ្នោតបោះតាមសំបុត្រត្រូវបានរាប់ វាត្រូវតែបិទតែមប្រៃសណីយ៍នៅ ឬមុនថ្ងៃបោះឆ្នោត ហើយបានទទួលដោយការិយាល័យបោះឆ្នោតប្រចាំខោនធីរបស់អ្នក មិនលើសពី 7 ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោតទេ។

### តើការបោះឆ្នោតរបស់ខ្ញុំមានសុវត្ថិភាពទេ?

បាទ រដ្ឋកាលីហ្វ័រញ៉ាដាក់កម្រិតលើសពីលក្ខខណ្ឌតម្រូវរបស់សហព័ន្ធសម្រាប់សន្តិសុខការបោះឆ្នោត។ រាល់ការបោះឆ្នោតត្រូវតែបោះលើសន្លឹកឆ្នោតក្រដាស ឬមានសន្លឹកឆ្នោតដែលផ្ទៀងផ្ទាត់សន្លឹកឆ្នោត។ ឧបករណ៍បោះឆ្នោតដែលប្រើដើម្បីបោះ និងរាប់សន្លឹកឆ្នោតត្រូវតែមានវិញ្ញាបនបត្រសម្រាប់ប្រើប្រាស់ក្នុងរដ្ឋកាលីហ្វ័រញ៉ា ហើយរក្សាទុកដោយគ្មានអ៊ីនធឺណិត។ មន្ត្រីរៀបចំបោះឆ្នោតធ្វើសវនកម្មក្រោយការបោះឆ្នោត រួមទាំងការរាប់សន្លឹកឆ្នោតដោយដៃ បន្ទាប់ពីការបោះឆ្នោតនីមួយៗ ដើម្បីធានាបាននូវភាពត្រឹមត្រូវ និងសុចរិតភាពនៃការរាប់សន្លឹកឆ្នោត។ អ្នកបោះឆ្នោតអាចស្វែងរកព័ត៌មានអំពីការបោះឆ្នោតជាផ្លូវការ និងគួរឱ្យទុកចិត្ត ក៏ដូចជាស្វែងយល់បន្ថែមអំពីការការពារសុវត្ថិភាពការបោះឆ្នោតរបស់យើង និងកិច្ចខិតខំប្រឹងប្រែងសម្រាប់កិច្ចការពារសុវត្ថិភាពតាមអ៊ីនធឺណិតតាមគេហទំព័រ sos.ca.gov/elections/election-cybersecurity។

### តើខ្ញុំអាចទទួលបានលទ្ធផល បោះឆ្នោតទាន់ហេតុការណ៍ដោយរបៀបណា ?

- ការរាប់សន្លឹកឆ្នោតទូទាំងរដ្ឋអាចរកបាននៅ electionresults.sos.ca.gov
- តាមដានយើងនៅលើ X @CASOSvote

registertovote.ca.gov

បានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី 05/22/24